គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)
ទីស្នាក់ការកណ្ដាលផ្ទះលេខ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 Fax: (855) 23 885 745
E-mail: comfrel@online.com.kh Website: http://www.comfrel.org

ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

1.លោក ធន សារាយ
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

2.លោក សុក សំអឿន
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

3.លោក យង់ គិមអេង
Mr. YONG Kim Eng
អគ្គលេខាធិការ -នាយកប្រតិបត្តិ
PDP-Center

4.លោក យឹម ប៉ូ
Mr. YIM Po នាយករង
CPDEW

5.អ្នកស្រី ស៊ុន ចាន់សែន
Mrs. SUN Chansen
ឥស្សរជន- Dignitary

6.លោក ម៉ាក់ ចំរើន
Mr. MAK Chamroeun
ប្រធាន KYA

7.អ្នកស្រី ប៉ុក បញ្ញាវិចិត្រ
Mrs. POK Panhavichetr
នាយិកាប្រតិបត្តិ CWCC

8.លោក មុំ សារិន
Mr. MOM Sarin
នាយក HRCDO

9.លោកស្រី ពឹង យក់ហៀប
Ms. PEUNG Yok Hiep
ឥស្សរជន-Dignitary

10. លោក គីម សុវណ្ណ
Mr. KIM Sovann
នាយក VIGILANCE

11.លោក សេន សែត
Mr. SEN Set
ឥស្សរជន-Dignitary

12. លោក ជាង សុខា
Mr. CHEAMG Sokha
នាយកប្រតិបត្តិ YRDP

ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២

# សេចក្ដីថ្លែងការណ៍
# ស្ដីពី
# ការព្រួយបារម្ភចំពោះអំពើឃាតកម្មលើអ្នកការពារសិទ្ធិ ក្នុងដំណាក់កាលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១២

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) សូមចូលរួមសម្ដែងមរណៈទុក្ខយ៉ាងក្រៀមក្រំចំពោះគ្រួសារនៃសព របស់លោក **ឈុត វុទ្ធី** ប្រធានអង្គការការពារធនធានធម្មជាតិ ដែលត្រូវបានសម្លាប់កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ ក្នុងពេលដែលលោកកំពុងបំពេញបេសកម្មការពារព្រៃឈើក្នុងចំណុចវាលបី ភូមិបាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។

ខុមហ្វ្រែល សូមសម្ដែងនូវការព្រួយបារម្ភជាខ្លាំងចំពោះករណីឃាតកម្មទៅលើអ្នកការពារសិទ្ធិ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិយាកាសនយោបាយ និងបង្កើតបរិយាកាសភ័យខ្លាច ក្នុងចំណោមសកម្មជនសង្គម បរិស្ថាន នយោបាយ សិទ្ធិមនុស្ស ហើយក៏អាចគម្រាមកំហែងដល់សេរីភាពប្រជាពលរដ្ឋក្នុងការចូលរួមការងារសង្គម និងសកម្មភាពនយោបាយ ពិសេសនៅខេត្តកោះកុង ក្នុងដំណាក់កាលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាឆ្នាំ២០១២ និងបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ ខាងមុខនេះ។

ខុមហ្វ្រែល សូមធ្វើការថ្កោលទោសយ៉ាងខ្លាំងក្លាបំផុតចំពោះមេខ្លោង និងអ្នកសមគំនិត រួមទាំងបុគ្គលសមត្ថកិច្ចកងកម្លាំងប្រដាប់អាវុធ ដែលបានប្រព្រឹត្តឡើងនូវអំពើហឹង្សាឃោរឃៅ និងអំពើខុសច្បាប់ទៅលើលោក ឈុត វុទ្ធី និងអ្នកសារព័ត៌មានស្ត្រី នៃព្រឹត្តិបត្រឌឹខេមបូឌាដេលី កញ្ញា **ផន បុប្ផា** និង Olesia Plokhii ហើយសូមធ្វើការអំពាវនាវយ៉ាងទទូចដល់រដ្ឋាភិបាល និងស្ថាប័នមានសមត្ថកិច្ច ដើម្បីចាត់វិធានការជាបន្ទាន់ក្នុងការរែករកមុខក្រុមឃាតករ និងអ្នករួមគំនិត ដើម្បីបង្កើតបរិយាកាសទុកចិត្តទៅលើប្រព័ន្ធយុត្តិធម៌ ឬដោយឡែកការងារអង្កេតរបស់សមត្ថកិច្ច។ រាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់ពង្រឹងសមត្ថភាពយល់ដឹងផ្លូវច្បាប់អំពីការប្រើប្រាស់អាវុធដល់មន្ត្រី និងកងកម្លាំងប្រដាប់អាវុធបន្ថែមទៀតដើម្បីរួមចំណែកទប់ស្កាត់អំពើហិង្សាប្រដាប់អាវុធ។ ខុមហ្វ្រែល នឹងវាយតំលៃខ្ពស់ចំពាះរាជរដ្ឋាភិបាល នូវការបង្ហាញមនោសញ្ចេតនាក្នុងការទទួលស្គាល់វីរៈភាពអ្នកការពារសិទ្ធិ ដូចជា លោក ឈុត វុទ្ធី ក្នុងការចូលរួមការពារធនធានធម្មជាតិ និងព្រៃឈើកម្ពុជា។

ខុមហ្វ្រែល គោរពចំពោះការលះបង់ និងគំរូសកម្មភាពរបស់លោក ឈុត វុទ្ធី ជាការរំឭក និងលើកទឹកចិត្តសកម្មជន អ្នកសង្កេតការណ៍បោះឆ្នោតរបស់ខ្លួនក្នុងបុព្វហេតុការពារយុត្តធម៌ និងសេរីភាពក្នុងការបោះឆ្នោត។

ខុមហ្វ្រែល អំពាវនាវយ៉ាងទទូចដល់រាជរដ្ឋាភិបាល កងកម្លាំងការពារសន្តិសុខ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរកគ្រប់វិធានការណ៍បញ្ចៀសអំពើហឹង្សា និងគំរាមកំហែងនានាប្រឆាំងសកម្មជនសង្គម សិទ្ធិមនុស្ស និងនយោបាយក្នុងកំឡុងពេលបោះឆ្នោត៕

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

លោក **គល់ បញ្ញា** (នាយកប្រតិបត្តិ ខុមហ្វ្រែល) / ទូរស័ព្ទលេខ ៖ ០១២ ៩៤ ២០ ១៧